# ខ្លឹមសារជំនឿលើព្រះយេស៊ូវគ្រីស្ទ ក្នុង៦មេរៀន

## មេរៀនទី៣ ការអស្ចារ្យនៃសេចក្តីស្រលាញ់របស់ព្រះ

លំនាំដើម ការរំលឹក

**តើព្រះរបស់គ្រិស្ទបរិស័ទជានរណា?**

- ព្រះអាទិករ គឺព្រះយេហូវ៉ា មានព្រះជន្មរស់ទាំងពីអសកល្ប ទ្រង់គ្មានខួបកំណើត គ្មានទីបំផុត ទ្រង់មានគ្រប់អំណាចព្រះចេស្តា គ្រប់ប្រាជ្ញាញាណជ្រាបទាំងអស់ ល្អបរិសុទ្ធគ្រប់ជំពូក និងមានសេចក្តីស្រលាញ់ ព្រះមានទំនាក់ទំនងជាមួយមនុស្ស
- ព្រះបង្កើតមនុស្ស ឲ្យមានរូប ហើយមានភាពដូចជាព្រះអង្គខ្លះ គឺមានប្រាជ្ញា ចេតនា និងឆន្ទៈ។ ព្រះបង្កើតមនុស្សខុសគ្នាពីសត្វ ព្រោះមនុស្សមានទំនងជាមួយព្រះបាន។
- ព្រះអង្គប្រទានការងារឲ្យមនុស្សដែរ គឺ ១) គ្រប់គ្រងលើផែនដីនូវជំនួសព្រះ ២) កើតកូនឲ្យមានមនុស្សពាសពេញលើផែនដី ៣) ហើយធ្វើជាតំណាងព្រះ ដើម្បីថ្វាយសិរីល្អដល់ទ្រង់។

ព្រះគម្ពីរចែងថា **«ឱព្រះអម្ចាស់ ជាព្រះនៃយើងរាល់គ្នាអើយ ទ្រង់គួរនឹងទទួលសិរីល្អ កិត្តិនាម នឹងព្រះចេស្តា ដ្បិតទ្រង់បានបង្កើតរបស់សព្វសារពើមក ហើយគឺដោយបំណងព្រះហឫទ័យទ្រង់ហើយ ដែលរបស់ទាំងនោះបានកើតមក ហើយមាននៅផង។»** វិវរណៈ ៤:១១

~

ខគម្ពីរដែលប្រហែលជាល្បីល្បាញជាងគេគឺ
**«ដ្បិតព្រះស្រឡាញ់មនុស្សលោកជាខ្លាំង បានជាទ្រង់ប្រទានព្រះរាជបុត្រាតែមួយរបស់ព្រះអង្គ ដើម្បីឲ្យអ្នកណាដែលជឿដល់ព្រះរាជបុត្រានោះ មិនត្រូវវិនាសឡើយ គឺឲ្យមានជីវិតអស់កល្បជានិច្ចវិញ»។** យ៉ូហាន ៣:១៦

**«ដ្បិតព្រះស្រឡាញ់មនុស្សលោកជាខ្លាំង»**

ពាក្យនេះអស្ចារ្យណាស់! ព្រះដែលខ្ពង់ខ្ពស់ជាអ្វីៗទាំងអស់ ហើយបរិសុទ្ធ ទ្រង់ស្រលាញ់មនុស្សលោក!

តើមនុស្សយើងសមនឹងទទួលសេចក្ដីស្រលាញ់នោះពីព្រះទេ? តើព្រះគួរ ឬមិនគួរ ស្រលាញ់យើង? បើទ្រង់ស្រលាញ់យើង នោះប្រកបដោយយុត្តិធម៌ទេឬអី?

ដើម្បីឆ្លើយតបតាំសំណួរទាំនេះកើត យើងត្រូវដឹងដសាច់រឿងរបស់ជីដូនជីតាដំបូងបំផុតរបស់មនុស្សលោកជាមុនសិន។

## ជីដូនជីតាដំបូងបំផុតរបស់មនុស្សលោក

ជីដូនជីតាដំបូងបំផុតរបស់មនុស្សលោកទាំងអស់ គឺប្រុសនិងស្រីដំបូងដែលព្រះអង្គបង្កើតមុនគេ គឺលោកអ័ដាម និងនាងអេវ៉ា។ ព្រះបានបង្កើតលោកអ័ដាមមុន។

**«ព្រះយេហូវ៉ាដ៏ជាព្រះបានយកធូលីដី មកសូនធ្វើជាមនុស្ស ហើយព្រះអង្គផ្លុំខ្យល់ដង្ហើមជីវិតបញ្ចូលទៅក្នុងរន្ធច្រមុះគេ នោះមនុស្សក៏មានជីវិតរស់ឡើង»**

លោកុប្បត្តិ ២:៧

ព្រះបានបង្កើតមនុស្សពីធូលីដីមក ហើយផ្តល់ជីវិតឲ្យគេ។ បន្ទាប់មកទ្រង់បង្កើតស្រី។

**«ព្រះយេហូវ៉ាដ៏ជាព្រះទ្រង់មានព្រះបន្ទូលថា៖ «ដែលមនុស្សប្រុសនៅតែម្នាក់ឯងមិនស្រួលទេ យើងនឹងបង្កើតអ្នកជំនួយម្នាក់ឲ្យបានជាគ្នា»**

**«ព្រះយេហូវ៉ាដ៏ជាព្រះធ្វើឲ្យមនុស្សដេកលក់ រួចព្រះអង្គយកឆ្អឹងជំនីររបស់គាត់មួយ ហើយភ្ជិតសាច់ទៅវិញ ហើយឆ្អឹងដែលព្រះយេហូវ៉ាដ៏ជាព្រះបានយកពីបុរសមក ព្រះអង្គបានធ្វើឲ្យទៅជាស្ត្រី ហើយក៏នាំនាងមកជួបបុរសនោះ។»**

លោកុប្បត្តិ ២:១៨, ២១-២២

ទ្រង់បង្កើតលោកអ័ដាម និងនាងអេវ៉ាបរិសុទ្ធល្អឥតខ្ចោះ។ លោកទាំងពីរមានសេចក្តីស្រលាញ់គ្នាដ៏គ្រប់លាក់ គ្មានអ្វីរាំងការទំនាក់ទំនងរបស់គាត់ទេ។

***សកលលោកនេះមិនបានបង្កើតខ្លួនវាទេ! គ្មានបុគ្គលណា ឬវត្ថុណាដែលបង្កើតខ្លួនបានទេ! ផ្ទុយទៅវិញអ្វីៗទាំងអស់មានអ្នកបង្កើតវា លើកលែងតែព្រះអាទិករ។

## ដើមឈើពីរ

ក្នុងសួនធំស្អាតដែលព្រះឲ្យលោកទាំងពីរនៅ មានដើមឈើពីរ មានដើមឈើជីវិតមួយ ហើយដើមឈើដឹងខុសត្រូវមួយទៀត។ អ្នកណាដែលបរិសុទ្ធបរិភោគពីដើមជីវិតបាន ដូច្នេះអ័ដាមនិងអេវ៉ាបរិភោគបានមិនអីទេ។ តែដើមដឹងខុសត្រូវព្រះអង្គហាមកុំឲ្យញុំា បើសិនញុំា លោកទាំងពីរពិតជាស្លាប់មិនខាន។

នៅពេលនោះមិនទាន់មានសេចក្តីស្លាប់ទេ គ្មានកំហុស គ្មានបាប ហើយគ្មានការរងទុក្ខ។ ព្រះអង្គស្រលាញ់គាត់ណាស់ ហើយលោកទាំងពីរឃើញព្រះ មានតែការរីករាយនឹងសេចក្តីសុខសាន្ត។ បើអ័ដាមនិងអេវ៉ាទុកចិត្តលើព្រះ ហើយគោរពជឿព្រះបន្ទូលរបស់ព្រះ ការរីករាយនឹងសេចក្តីសុខសាន្តមានដដែល។

## វិញ្ញាណអាក្រក់

ទោះបើជាព្រះបានបង្កើតសកលលោកល្អប្រពៃក៏ដោយ ការអាក្រក់មានវត្តមានឡើង។ ក្នុងចំណោមពួកទេវតាដែលទ្រង់បង្កើតមក ១ភាគក្នុង៣បានបះបោរ

ប្រឆាំងនិងព្រះ លទ្ធផលអំពើអាក្រក់មានឡើង។ ទ្រង់ចាប់មួយចំនួនទំលាក់វា ក្នុងជំហុកដ៏ធំជាប់ចំណងដែលពួកវាគេចមិនបាន។ តែមួយចំនួនទៀត ព្រះ ដេញពីស្ថានសួគ៌ទំលាក់ដល់ផែនដី។ ទេវតាអាក្រក់នោះ មានមេកំណាចដ៏ធំ ជាងគេរបស់វាឈ្មោះថា សាតាំង។  វានៅផែនដី ហើយវាជាសត្រូវរបស់ព្រះ។

## អំពើបាបរបស់លោកទាំងពីរ

ថ្ងៃមួយអារក្សសាតាំង ដ៏ជាមេកំណាច វាបន្លំខ្លួនវាមកល្បួងនាងអេវ៉ា។ វាខំនាំ អេវ៉ាឲ្យសង្ស័យនូវចំពោះព្រះបន្ទូលរបស់ទ្រង់ ហើយខំនាំនាងសង្ស័យនិងសេច ក្តីស្រលាញ់របស់ព្រះ។ វាចង់នាំឲ្យនាងញ៉ាំផ្លែឈើដែលព្រះហាមឲ្យញ៉ាំ លទ្ធផល បំផ្លាញមនុស្ស ហើយបង្ខូចផែនដីដែលព្រះបានបង្កើតមក។

ក្រោយមក នាងបានបរិភោគផ្លែពីដើមដឹងខុសត្រូវ ហើយលោកអ័ដាមក៏បាន បរិភោគតាម។ ឥឡូវលោកទាំងពីរមានបាប មានទោសនៅចំពោះព្រះហើយ។ ឥឡូវមនុស្សបានបះបោរប្រឆាំងនិងព្រះ ដូចទេវតាអាក្រក់ ដូច្នេះមនុស្សប្តូរម្ចាស់ ប្តូរពីព្រះមកក្រោមមេកំណាចវិញ។

**«លោកីយ៍ទាំងមូលដេកនៅក្នុងអំណាចរបស់មេកំណាច។»** ១ យ៉ូហាន ៥:១៩

## ព្រះបន្ទូលបណ្តាសាទៅកាន់មនុស្ស

ព្រះអង្គក៏មានព្រះបន្ទូលទៅស្ត្រីថា៖ «**យើងនឹងធ្វើឲ្យនាង មានសេចក្តីព្រួយលំបាកជាច្រើន នៅពេលមានផ្ទៃពោះនាងនឹងសម្រាលកូនទាំងឈឺចុកចាប់ ចិត្តនាងនឹងប្រាថ្នាចង់បានប្តី ហើយប្តីនឹងត្រួតត្រាលើនាង**»។

ព្រះអង្គមានព្រះបន្ទូលទៅអ័ដាមថា៖

«**នោះដីនឹងត្រូវបណ្តាសាដោយសារអ្នក អ្នកនឹងរកស៊ីពីដីដោយនឿយហត់អស់មួយជីវិត។ ដីនឹងដុះចេញជាបន្លា និងអញ្ចាញឲ្យអ្នក ហើយអ្នកនឹងបរិភោគតិណជាតិទាំងឡាយ ដែលដុះនៅតាមទីវាល។ អ្នកនឹងបានអាហារបរិភោគដោយការបែកញើស រហូតដល់អ្នកត្រឡប់ទៅជាដីវិញ ដ្បិតយើងបានយកអ្នកពីដីមក អ្នកជាធូលីដី ហើយអ្នកនឹងត្រឡប់ ទៅជាធូលីដីវិញ**»។

សេចក្តីស្លាប់និងការរលួយចូលក្នុងពិភពលោក។ ឥឡូវមនុស្សដាច់ចេញពីព្រះ មានទោស ចិត្តកំនិតរបស់គេខូចខាត ហើយរូបកាយត្រូវស្លាប់។ ជំងឺ មេរោគ សង្គ្រាម ការរងទុក្ខគ្រប់បែបយ៉ាងត្រូវជាបទពិសោធរបស់មនុស្សហើយ។

«**អ្វីៗសព្វសារពើដែលព្រះបង្កើតមក នៅជាប់ចំណងនៃសេចក្តីពុករលួយដោយព្រោះបាបរបស់មនុស្សដែរ។ អ្វីៗសព្វសារពើទាំងអស់ដែលព្រះបង្កើតមកកំពុងស្រែកថ្ងូរទាំងឈឺចាប់ដូចស្ត្រីហៀបសម្រាលកូន រហូតមកទល់ពេលនេះ។**» រ៉ូម ៨:២១-២២

ហេតុអ្វីទាំងអស់នេះកើតឡើង? ពីព្រោះបាបដែលមនុស្សនាំចូលក្នុងលោកនេះ។ ដូច្នេះព្រះបានដេញលោកទាំងពីរចេញពីសួនច្បារអេដែន ពីព្រោះគាត់មិនអាចបរិភោគពីដើមឈើជីវិតទៀងមិនបានទេ។

មួយទៀត យើងទាំងអស់គ្នា មានទោសនៅចំពោះព្រះ យើងបានធ្វើតាមលោកតាលោកយាយដើម យើងទាំងអស់គ្នាបានដាច់ចេញពីព្រះដូចគ្នា។ យើងទាំងអស់គ្នាត្រូវបណ្ដាសាព្រះ នៅក្រោមអំណាចរបស់អារក្សសាតាំង។

## តើព្រះអង្គគួរស្រលាញ់មនុស្សលោក?

## មិនមែនទេ! មិនសមឡើយ!

តែព្រះគម្ពីរបានចែងថា«**ដ្បិតព្រះស្រឡាញ់មនុស្សលោកជាខ្លាំង**»។ តើពាក្យនេះមានន័យយ៉ាងម៉េច? តើមនុស្សយើងដែលបានបែកចេញពីព្រះរួចហើយ ជានានឹងព្រះអង្គដ៏បរិសុទ្ធនិងយុត្តិធម៌យ៉ាងម៉េចបាន? យើងនឹងឆ្លើយតបតាំមសំណួរទាំងនេះនូវមេរៀនបន្តបន្ទាប់។